# គំនូរក្នុងរូងភ្នំ «ពើងតាខាប» ភ្នំគូលែន

ព្រះរាជាណាចក្រកម្ពុជាមានតំបន់ការពារធម្មជាតិជាច្រើនកន្លែង ដែលត្រូវបានកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ។ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ជាផ្នែកមួយនៃតំបន់ការពារធម្មជាតិ ដែលមានផ្ទៃដីសរុបចំនួន ៣៧៥០០ ហិចតា និងមានតួនាទីសំខាន់ក្នុងការរក្សាលំនឹងបរិស្ថាននៅតំបន់អង្គរ ដោយសារប្រភពធនធានធម្មជាតិ ព្រៃឈើ ប្រភពទឹក និងជីវចម្រុះ ដែលមាននៅទីនោះ ។ ក្នុងនោះភ្នំគូលែនជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់មួយ ដែលបានរក្សាទុកនៅមរតកវប្បធម៌ជាច្រើន និងជាអតីតរាជធានីរបស់ព្រះបាទជ័យវរ្ម័នទី២ ។ មានប្រាសាទបុរាណជាច្រើន ដោយរួមទាំងចម្លាក់នៅបាតស្ទឹង ព្រមទាំងមរតកវប្បធម៌ផ្សេងៗទៀតដែលមាននៅទីនោះ ដោយពុំទាន់បានសិក្សា និងផ្សព្វផ្សាយពេញលេញនៅឡើយ ។

ហេតុអ្វីបានជាព្រះបាទជ័យវរ្ម័នទី២ ជ្រើសរើសភ្នំគូលែនជារាជធានី? ជាទូទៅ ការកសាងរាជធានីច្រើនតែធ្វើឡើងនៅលើទីតាំងដែលធ្លាប់មានមនុស្សរស់នៅ និងជាទីតាំងដែលមានសក្តានុពលពីធម្មជាតិ ព្រមដោយជំនឿផងដែរ។ ក្រៅអំពីរចនាសម្ព័នទីក្រុង និងប្រាសាទបុរាណ តើភ្នំគូលែនមានសំណល់អ្វីផ្សេងទៀត?

តំបន់ភ្នំគូលែន ក៏មានគំនូរក្នុងរូងភ្នំផងដែរ ។ គួរឱ្យកត់សម្គាល់ដែរថា គំនូរត្រូវបានមនុស្សប្រើប្រាស់ជាយូរណាស់មកហើយ តួយ៉ាងដូចជាគំនូរនៅរូងភ្នំ Lascaux ប្រទេសបារាំង ដែលមានអាយុកាលចន្លោះ ៣៥០០០ឆ្នាំ-១០០០០ឆ្នាំ[១] ហើយដែលជាគំនូរក្នុងរូងភ្នំដ៏ចំណាស់។ ទន្ទឹមនឹងនោះ នៅតំបន់អាស៊ីក៏មានគំនូរនៅតាមរូងភ្នំផងដែរ ឧទាហរណ៍ដូចជា គំនូរនៅប្រទេសថៃ ដែលជាគំនូរលាបពណ៌ក្រហមដែលបង្ហាញអំពីមនុស្សបាញ់ព្រួញ និងសត្វគោ ដែលគេបានកំណត់អាយុចន្លោះ ៤០០០ ទៅ២៥០០ ឆ្នាំមុនពេលបច្ចុប្បន្ន។[២] ក្នុងប្រទេសកម្ពុជា គេបានរកឃើញគំនូរនៅពើងគំនូរ ភ្នំក្រវាញ នៅពើងគំនូរ និងពើងតាខាបនៅភ្នំគូលែន។ គំនូរនៅតាមរូងភ្នំក៏ធ្លាប់បានសិក្សាដោយលោក ហេង ថាន។

---

[១] https://hoopermuseum.earthsci.carleton.ca/2001_human_ka/genushomo18.html

[២] Noel Hidalgo Tan, 2014: p76

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ក្នុងនោះ លោកអ្នកបានបង្ហាញគំនូរនៅតាមពើងមួយចំនួនដែលនៅតាមចង្កេះភ្នំគូលែន ដូចជាពើងកោប ពើងវាលព្រះបាទ ពើងដែរ ពើងគំនូរ និងពើងល្អងធំ។[៣]

ពើងតាខាប ស្ថិតនៅក្នុងភូមិថ្មី ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប ដែលមានចំនុចនិយាមការ X= 404640 Y= 1496523។[៤] ពើងតាខាប ជាប្រភេទថ្មភក់ ដែលជាថ្មមួយដុំធំ មានទំហំប្រមាណ២០ម៉ែត្រ រីកធំផ្នែកខាងលើ និងរាងតូចនៅផ្នែកខាងក្រោម ដែលអាចឱ្យមនុស្សជ្រកបាន(រូបលេខ១) និងមានពើងថ្មនៅក្បែរនោះជាច្រើនផងដែរ។ យើងបានប្រទះឃើញស្នាមគំនូរពណ៌ក្រហមព្រៀលៗនៅពើងតាខាបនេះ។ គំនូរទាំងនោះមានភាពរលប់ ហើយនៅសល់ស្នាកស្នាមតែបន្តិចបន្តួចប៉ុណ្ណោះ។ ជាការកត់សម្គាល់ គំនូរទាំងនេះស្ថិតនៅ លើជញ្ជាំងថ្ម ក្បែររូបចម្លាក់ព្រះគណេសដែលជាចម្លាក់ថ្មី (រូបលេខ២)។ បច្ចុប្បន្នទីតាំងនេះ គឺជាទីតាំងសំណាក់ធម៌ ។

គំនូរនៅពើងតាខាបរួមមានបង្ហាញអំពី រូបមនុស្ស និងរូបសត្វ ៖

១. រូបមនុស្ស ឈរ មានកម្ពស់ប្រមាណ៣៥ស.ម។ ផ្នែក ក្បាលជាគំនូសរង្វង់ៗច្រើនជាន់ ពីតូចមកធំ។ ដងខ្លួនលាបពណ៌ក្រហមពេញ ដៃខាងឆ្វេងមានស្នាមជាម្រៀម ៣ និងខាងស្តាំមើលមិនឃើញម្រាមទេ ចំណែកជើងទាំងពីរឈរស្របគ្នាត្រង់(រូបលេខ៣)។

២. រូបសត្វ ប៉ុន្តែហាក់មិនមានរូបរាងដែលអាចកំណត់ ច្បាស់លាស់ថា ជាសត្វអ្វីនោះទេ? តាមរយៈទម្រង់នោះ គឺប្រហែលជារូបសត្វពាហនៈ ឬអាចជាសត្វគោ? ដែលមានទំហំប្រមាណ ៣០ស.ម និងឈរនៅពីមុខរូបមនុស្ស។ ក្នុងនោះដែរ ជើងក្រោយទាំងពីរ ដែលមានម្រាមជើង២ និងកន្ទុយ គឺអាចនៅកំណត់បានច្បាស់។ ដោយឡែក ផ្នែកខាងមុខរលប់ខ្លាំង និងពិបាកកំណត់រូបរាងថាជាអ្វី (រូបលេខ៤) ។ ដោយឡែក គំនូរត្រង់នេះតើអាចនឹងបង្ហាញអំពីទំនាក់ទំនងរវាងមនុស្ស និងការសត្វចិញ្ចឹមដែរឬទេ?

៣. រូបភាពជារង្វង់មូល(រូបលេខ៥) ដែលមានទម្រង់ពីតូចទៅធំ ប្រមាណជាទំហំ ១០ស.ម ក៏ប៉ុន្តែគ្មានដៃជើងនោះទេ ដែលទំហំនេះប្រហាក់ប្រហែលគ្នា និងរូបក្បាលមនុស្សដែលបានបញ្ជាក់ក្នុងចំណុចទី១។ នៅមានស្នាកស្នាមគំនូររូបផ្សេងៗនៅក្បែរនោះ

---

[៣] កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ, ឆ្នូ២០០៩-ឆ្នូ២០១០: ទំព័រ៩០

[៤] បញ្ជីបុរាណស្ថាន ក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន», ឆ្នាំ២០១៥, ទំព័រ១៣១

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ផងដែរ តែមិនអាចមើយល់ថាជារូបអ្វីនោះទេ? ត្រង់ចំណុចត្រង់នេះអាចជាការប្រសើរណាស់ ប្រសិនបើរូបគំនូរទាំងនេះអាចនឹងបានសិក្សា និងថតរូបដោយប្រើប្រាស់បច្ចេកទេសទំនើប ឬតួយ៉ាងដូចជាបច្ចេកទេសដែលធ្លាប់ប្រើប្រាស់ដើម្បីថតរូបគំនូរ នៅប្រាសាទអង្គរវត្តជាដើម។

៤. ក្រៅពីរូបគំនូរ នៅផ្ទៃខាងក្រោមក្បែរគំនូរនោះ មានស្នាកស្នាមរន្ធមូលតូចៗជាច្រើន ហើយរន្ធដែលធំជាងគេមានទំហំប្រមាណ១០ស.ម(រូបលេខ៦)។ រន្ធនេះមិនមែនជារន្ធដែលកើតឡើងដោយសំណឹកថ្មនោះទេ ប៉ុន្តែបានបង្កើតដោយមនុស្ស ។ ដោយឡែកមិនមានពត៌មានអំពីតួនាទីនៃរន្ធទាំងនោះទេ? តើរន្ធទាំងនេះមានទំនាក់ទំនងនឹងគំនូរដែរឬទេ?

សរុបសេចក្តីមក ទីតាំងគំនូរនេះមិនទាន់មានការសិក្សាស្រាវជ្រាវ បែបវិទ្យាសាស្ត្រនៅឡើយទេ។ តាមរយៈបច្ចេកទេសគូរ អាចកំណត់ថាគំនូរទាំងនេះមានអាយុចំណាស់។ ស្នាកស្នាមដែលជារង្វង់ៗទាំងនេះធ្លាប់បានបង្ហាញនៅលើខ្ទមផ្ទាំង សម័យបុរេប្រវត្តិសាស្ត្រ។ ចំពោះសំនួរថាតើគំនូរទាំងនេះបានគូរតាំងពីពេលណា? តើវាស្ថិតនៅក្នុងសម័យស្របគ្នានឹងការតាំងទីព្រះពជរាំងនៅលើភ្នំគូលែន ឬមានវ័យចំណាស់ជាង? យើងសង្ឃឹមថាសំនួរទាំងនេះនឹងអាចស្រាយបំភ្លឺនៅពេលណាដែលគំនូរទាំងនេះ បានសិក្សាស្រាវជ្រាវច្បាស់លាស់។ លើសពីនេះ ការសិក្សានឹងផ្តល់សារសំខាន់បន្ថែមទៅលើសិល្បៈគំនូររូងភ្នំ ដែលកម្មរបស់កម្ពុជា។

**ឯកសារយោង**

កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ
ឆ្នូ២០០៩-ឆ្នូ២០១០. ទំព័រ៩០, ភ្នំពេញ
ក្រសួងបរិស្ថាន
ឆ្នាំ២០១៥. បញ្ជីបុរាណស្ថានក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន», ទំព័រ១៣១
Noel Hidalgo Tan,
2014 Rock Art Research in Southeast Asia: A Synthesis, p76
https://hoopermuseum.earthsci.carleton.ca/2001_human_ka/genushomo18.html

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១ ពើងតាខាប



រូបលេខ២ គំនូរលើជញ្ជាំងថ្ម

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៣ គំនូរមនុស្ស

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័



រូបលេខ៖ រូបមនុស្ស៤



រូបលេខ៥

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៦

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION